**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសព័ត៌មាន

# សារលិខិតរបស់ឯកឧត្តមខេវិន រ៉ាត់ក្នុងឱកាសពិធីបុណ្យរ៉ាម៉ាដាន់

ខាងក្រោមនេះជាប្រសាសន៍របស់លោករដ្ឋមន្ត្រីការបរទេសអូស្ត្រាលី ឯកឧត្តម **ខេវិន រ៉ាត់** (Kevin Rudd) សំដែងអំពីការជូនពររបស់លោកចំពោះសាសនិកជនឥស្លាមទាំងអស់ក្នុងឱកាសពិធីបុណ្យរ៉ាម៉ាដាន់។

ខ្ញុំសូមគោរពជូនពរសាសនិកជនឥស្លាមទាំងអស់ដែលរស់នៅទាំងក្នុងប្រទេសអូស្ត្រាលី និងពិភពលោកទាំងមូលក្នុងឱកាសពិធីបុណ្យខែបួសរ៉ាម៉ាដាន់។

សម្រាប់សាសនិកជនឥស្លាមជាង 1,5 ពាន់លាននាក់ នៅលើពិភពលោក ពិធីបុណ្យរ៉ាម៉ាដាន់ជាខែពិសេសដែលពួកគេតមអាហារ និងសូត្រធម៌។ វាក៏ជាពេលវេលាមួយដ៏ពិសិដ្ឋ សម្រាប់ភាវនា និងប្រតិបត្តិមេត្តាធម៌ ជាពេលដែលប្រជាជនឥស្លាមទាំងអស់ត្រូវបានលើកទឹកចិត្តឲធ្វើការបរិច្ចាក និងជួយដល់ជនប្រុសស្រីរបស់ពួកគេ។ ក្នុងរយៈពេលនេះ សាសនិកជនឥស្លាមនឹងតមមិនទទួលទានអាហារ-ភេសជ្ជៈ ក្នុងចន្លោះរវាងថ្ងៃរះនិងថ្ងៃលិច ដែលធ្វើឲពួកគេយល់ដឹងអំពីជីវិត និងបទពិសោធន៍របស់អ្នកដែលជួបការលំបាកជាងពួកគេ។

បច្ចុប្បន្ន ប្រទេសអូស្ត្រាលីមានប្រជាជនស្ទើរតែកន្លះលាននាក់ប្រកាន់សាសនាឥស្លាម។ សហគមន៍ឥស្លាមនៅប្រទេសអូស្ត្រាលីមានភាពចម្រុះ ដោយមានសមាជិកមានប្រវត្តិដើមកំណើតជនជាតិខុសៗគ្នាចំនួនជាង60ជនជាតិ។ ប្រជាជនដែលកាន់សាសនាឥស្លាមបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងប្រទេសអូស្ត្រាលីនាសម័យទំនើប និងជួយពង្រឹងទំនាក់ទំនងរវាងប្រទេសអូស្ត្រាលី ជាមួយ សហគមន៍ឥស្លាមដទៃទៀតនៅទូទាំងសកលលោក។

រដ្ឋាភិបាលបានប្តេជ្ញាចិត្តនឹងលើកកម្ពស់ចំណងទំនាក់ទំនងដែលមានស្រាប់ និងកាន់តែរីកចំរើនជាលំដាប់របស់ប្រទេសនេះ ជាមួយប្រជាជនឥស្លាមទូទាំងពិភពលោក។ ក្នុងសុន្ទរកថារបស់ខ្ញុំនៅឯកិច្ចប្រជុំជាន់ខ្ពស់របស់អង្គការសហប្រតិបត្តិការឥស្លាម(OIC) នៅទីក្រុងអាស្តាណា ប្រទេសកាស្សាក់ស្ថាន នាខែមិថុនា ឆ្នាំនេះ ខ្ញុំបានប្រកាសអំពីការតែងតាំងនូវបេសកជនពិសេសរបស់រដ្ឋាភិបាលប្រចាំការនៅអង្គការ OIC គឺលោក អាមេត ហ្វាអឺ (Ahmed Faour)។ លោក ហ្វាអឺ ជាជនជាតិអូស្ត្រាលីដែលប្រកាន់ សាសនាឥស្លាមជាន់ខ្ពស់ និងជានាយកប្រតិបត្តិរបស់ប្រៃសណីយ៍អូស្ត្រាលី នឹងចូលរួមធ្វើការដើម្បីបង្កើនការយល់ដឹង និងពង្រឹងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន។

ពិធីរ៉ាម៉ាដាន់ជាការក្រើនរំលឹកថា ប្រជាជនអូស្ត្រាលីដែលប្រកាន់សាសនាឥស្លាមកំពុងតែចូលរួមយ៉ាងផុលផុសក្នុងសង្គមជាតិអូស្ត្រាលី។ ខណៈពេលដែលយើងកំពុងរង់ចាំការចាប់ផ្តើមពិធីរ៉ាម៉ាដាន់ក្នុងសប្តាហ៍នេះ ខ្ញុំសូមគោរពជូនពរ ប្រជាជនអូស្ត្រាលីដែលប្រកាន់សាសនាឥស្លាមទាំងអស់ «សូមរីករាយបុណ្យរ៉ាម៉ាដាន់»។

ខេវិន រ៉ាត់
ថ្ងៃទី31 ខែកក្កដា ឆ្នាំ2011

**ទំនាក់ទំនងការផ្សាយ:**

លោក Dave Gordge ទូរស័ព្ទលេខ: +855 23 213 470
ស្ថានទូតអូស្ត្រាលី ភ្នំពេញ